ក្រសួងពាណិជ្ជកម្ម
លេខ ០៧៩ ព.ណ.គ.ក.ប.ប.ប្រក

# ប្រកាស
## ស្តីពី
# បែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ននិង/ឬសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចនានារបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ក្នុងគោលបំណងជំរុញការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចរបស់ គ.ប.ក. ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ៣.-**

គ.ប.ក. មានសមត្ថកិច្ចចេញវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប." ដែលជាសេនាធិការត្រូវទទួលបន្ទុកអនុវត្តវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចរបស់ គ.ប.ក. ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ៤.-**

បែបបទនិងនីតិវិធីក្នុងការចេញវិធានការផ្អាកជាបណ្តោះអាសន្នរបស់ គ.ប.ក. ត្រូវអនុវត្តដូចខាងក្រោម៖

១- តាមការស្នើរបស់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. ដោយមានមូលហេតុសមស្របអាចឱ្យជឿជាក់បានថាមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានបំពាន ឬអាចត្រូវបានបំពាន ហើយ គ.ប.ក. យល់ឃើញថាចាំបាច់ក្នុងការចេញវិធានការផ្អាកជាបណ្តោះអាសន្នដូចមានចែងក្នុងមាត្រា២៤នៃច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីដោះស្រាយបញ្ហាបន្ទាន់ក្នុងគោលបំណង៖

- ក- ទប់ស្កាត់ព្យសនកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ និង/ឬមិនអាចស្តារឡើងវិញបានដល់សេដ្ឋកិច្ច ឬដល់បុគ្គលណាមួយ ឬ
- ខ- ការពារផលប្រយោជន៍សាធារណៈក្នុងស្ថានភាពអាសន្ន។

២- វិធានការផ្អាកជាបណ្តោះអាសន្នរបស់ គ.ប.ក. ដូចមានចែងក្នុងចំណុចទី១នៃប្រការនេះអាចតម្រូវឱ្យបុគ្គលណាមួយ៖

- ក- ផ្អាកអានុភាពនៃការព្រមព្រៀង ឬសកម្មភាពណាមួយដែលសង្ស័យថាបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង។
- ខ- ធ្វើសកម្មភាពណាមួយឬមិនឱ្យធ្វើសកម្មភាពណាមួយ ប៉ុន្តែមិនតម្រូវឱ្យមានការបង់ប្រាក់ឡើយ។

៣- គ.ប.ក. អាចដកវិធានការផ្អាកជាបណ្តោះអាសន្នដូចមានចែងក្នុងចំណុចទី១នៃប្រការនេះវិញនៅពេលណាក៏បាន ដោយមានមូលហេតុសមស្របដែលអាចទទួលយកបាន។

៤- វិធានការផ្អាកជាបណ្ដោះអាសន្នទាំងឡាយដូចមានចែងក្នុងចំណុចទី១នៃប្រការនេះ ត្រូវអស់អានុភាព៖

ក- នៅពេលវិធានការផ្អាកជាបណ្ដោះអាសន្នត្រូវបានដកចេញក្រោមចំណុចទី៣នៃប្រការនេះ។

ខ- នៅពេល គ.ប.ក. ចេញសេចក្ដីសម្រេចលើករណីនោះ ឬ

គ- ក្នុងរយៈពេល១(មួយ)ឆ្នាំ ចាប់ពីថ្ងៃដែលចេញវិធានការផ្អាកជាបណ្ដោះអាសន្ន និងអាចចេញសារជាថ្មីទៀតបាន ដោយមានមូលហេតុសមស្រប។

**ប្រការ៥.—**

បែបបទនិងនីតិវិធីក្នុងការចេញសេចក្ដីសម្រេចរបស់ គ.ប.ក. ត្រូវអនុវត្តដូចខាងក្រោម៖

១- ក្រោយទទួលបានសំណើពីមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. នៅពេលបញ្ចប់ការស៊ើបអង្កេត គ.ប.ក. អាចចេញសេចក្ដីសម្រេចទៅកាន់បុគ្គលណាមួយអំពីការបំពានច្បាប់ស្ដីពីការប្រកួតប្រជែង ដោយយោងតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- សេចក្ដីសម្រេចត្រូវធ្វើឡើងសម្រាប់តែបុគ្គលណាមួយដែលពាក់ព័ន្ធ ហើយសេចក្ដីសម្រេចទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈ។

ខ- សេចក្ដីសម្រេចត្រូវបញ្ជាក់៖

- រយៈពេលឱ្យបំពេញលក្ខខណ្ឌតាមសេចក្ដីសម្រេច
- កាលបរិច្ឆេទដែលសេចក្ដីសម្រេចត្រូវផុតកំណត់។

២- សេចក្ដីសម្រេចត្រូវបញ្ជាក់ចំណុច ដូចខាងក្រោម៖

ក- អំណះអំណាងរបស់ គ.ប.ក. បង្ហាញថាមាត្រាណាមួយនៃច្បាប់ស្ដីពីការប្រកួតប្រជែងត្រូវបានបំពាន។

ខ- ឈ្មោះឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និង/ឬតំណាងស្របច្បាប់របស់ភាគី។

គ- សេចក្ដីបញ្ជាក់អំពីកាលបរិច្ឆេទនៃការបង់ប្រាក់ផាកពិន័យ និងសេចក្ដីលម្អិតពាក់ព័ន្ធដល់ការបង់ប្រាក់ផាកពិន័យ ដូចមានចែងក្នុងមាត្រា៣៥នៃច្បាប់ស្ដីពីការប្រកួតប្រជែង។

ឃ- សេចក្ដីបញ្ជាក់លម្អិតពាក់ព័ន្ធដល់វិធានការផ្សេងៗ ដូចមានចែងនៅក្នុងមាត្រា៣៧នៃច្បាប់ស្ដីពីការប្រកួតប្រជែង។

ង- ហេតុផលដែល គ.ប.ក. សម្រេចចេញសេចក្ដីសម្រេច។

គ.ប.ក. អាចចេញសេចក្ដីសម្រេចតម្រូវឱ្យចាត់វិធានការផ្សេងៗទៀត ដែល គ.ប.ក. យល់ឃើញថាចាំបាច់ក្នុងការកែលម្អការអនុវត្តសកម្មភាពប្រកួតប្រជែងបំពានច្បាប់។

**ប្រការ៦.—**

បុគ្គលណាមួយដែលមិនសុខចិត្តនឹងវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចរបស់ គ.ប.ក. អាចប្ដឹងតវ៉ាទៅ គ.ប.ក. ឱ្យពិនិត្យនិងសម្រេចឡើងវិញចំពោះវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចទាំងនេះក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចនោះ។ គ.ប.ក. ត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុង

រយៈពេល៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹងតវ៉ានោះ ក្នុងករណីបដិសេធលើបណ្ដឹងតវ៉ា **គ.ប.ក.** ត្រូវបញ្ជាក់អំពីសំអាងហេតុ។

ក្នុងករណី **គ.ប.ក.** បដិសេធលើបណ្ដឹងស្នើសុំឱ្យពិនិត្យឡើងវិញលើវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬ សេចក្ដីសម្រេច បុគ្គលនោះអាចប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីការបដិសេធនោះ។

**ប្រការ៧._**

វិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចរបស់ **គ.ប.ក.** អាចជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលបុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលបំពានច្បាប់ និងបុគ្គលពាក់ព័ន្ធទទួលបានសេចក្ដីជូនដំណឹងអំពីវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬ សេចក្ដីសម្រេចនោះ។

**ប្រការ៨._**

វិធានការផ្អាកជាបណ្ដោះអាសន្នត្រូវមានអានុភាពអនុវត្តភ្លាម ទោះបីមានបណ្ដឹងតវ៉ាក៏ដោយ។

សេចក្ដីសម្រេចត្រូវមានអានុភាពអនុវត្តនិងមិនអាចជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៀតឡើយ ក្នុងករណីដូចខាងក្រោម៖

ក- រយៈពេលសម្រាប់ការប្ដឹងតវ៉ាត្រូវបានផុតកំណត់ ឬ

ខ- ពេលតុលាការមានសមត្ថកិច្ចចុងក្រោយបានបដិសេធការប្ដឹងតវ៉ា។

**ប្រការ៩._**

ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលបំពានច្បាប់ និងបុគ្គលពាក់ព័ន្ធមិនអនុវត្តវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចរបស់ **គ.ប.ក.** មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវរាយការណ៍ជូន **គ.ប.ក.**។ **គ.ប.ក.** ត្រូវស្នើសុំជំនួយពីអាជ្ញាធរតុលាការមានសមត្ថកិច្ច ដើម្បីអនុវត្តវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចនេះ។

**ប្រការ១០._**

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវបញ្ជូនសេចក្ដីជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចរបស់ **គ.ប.ក.** ទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលបំពានច្បាប់ និងបុគ្គលពាក់ព័ន្ធទៅគេហដ្ឋាន ទីស្នាក់ការ ឬទីតាំងនៃការធ្វើធុរកិច្ចដោយផ្ទាល់ ឬតាមសំបុត្រអនុសិដ្ឋ ដោយត្រូវចុះនិទ្ទេស កាលបរិច្ឆេទ និងហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃនៃការប្រគល់ ទទួល។

ក្នុងករណីដែលបុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលបំពានច្បាប់ និងបុគ្គលពាក់ព័ន្ធបដិសេធមិនព្រមទទួលសេចក្ដីជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចនោះ ឬមិនមានម្ចាស់ ឬមិនមានតំណាងទទួល នោះមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវបិទសេចក្ដីជូនដំណឹងនោះនៅទីស្នាក់ការ ឬទីតាំងនៃការធ្វើធុរកិច្ច និងនៅសាលាឃុំ សង្កាត់។ បន្ទាប់ពីបានបិទផ្សាយរួច ឯកសារ

ទាំងអស់នោះត្រូវចាត់ទុកថាបានទទួលជាផ្លូវការដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលបំពានច្បាប់ និងបុគ្គលពាក់ព័ន្ធ។

**ប្រការ១១.—**

ក្នុងករណីមិនអាចកំណត់ទីកន្លែងសម្រាប់ប្រគល់ ទទួលនូវសេចក្ដីជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងវិធានការផ្អាកជាបណ្ដោះអាសន្ន និង/ឬសេចក្ដីសម្រេចបាន មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងតាមសារព័ត៌មាន ទស្សនាវដ្ដី វិទ្យុ ទូរទស្សន៍ គេហទំព័រ ព្រឹត្តិបត្រព័ត៌មាន និងបណ្ដាញទំនាក់ទំនងសង្គមរបស់អគ្គនាយកដ្ឋាន **ក.ប.ប.** ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ។

បន្ទាប់ពីបានផ្សព្វផ្សាយជាសាធារណៈដូចមានចែងក្នុងកថាខណ្ឌខាងលើ ឯកសារទាំងអស់នោះត្រូវចាត់ទុកថាបានទទួលជាផ្លូវការដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលបំពានច្បាប់ និងបុគ្គលពាក់ព័ន្ធនានា។

**ប្រការ១២.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.—**

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ